# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីធម៌មួយដែលសំដែងក្នុងសុត្តន្តបិដក
## ហៅថា សតិបដ្ឋាន់សូត្រ

web site: hoksavann.org

ថ្ងៃទី១ ឧសភា ២០០៥

សតិបដ្ឋានសូត្រនេះ ព្រះពុទ្ធសំដែងនៅក្នុងដែនកុរុ ប្រារព្ធចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិបដ្ឋាន៤ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីលះបង់សេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោសមនុស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ៨ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ សតិបដ្ឋាន ប្រែថាការដំកល់ស្មារតីមាន៤ប្រការគឺ ១- កាយានុបស្សនាសតិបដ្ឋាន ប្រែថាការដំកល់ស្មារតីពិចារណារឿយៗ នូវកាយដោយលក្ខណ:៥យ៉ាង គឺ ក- ដោយកំណត់ខ្យល់ដកដង្ហើមចេញចូល គឺខ្យល់ចូលកំណត់ថាចូល ខ្យល់ដកដង្ហើមចេញឲ្យដឹងថាដកដង្ហើមចេញ ត្រង់រន្ធចុងច្រមុះ ។ ខ- កំណត់ពិចារណាឥរិយាបថ៤ គឺការដេកដើរឈរអង្គុយត្រូវកំណត់ដឹង ជាពិសេសគ្រប់ចលនាការកំរើករាងកាយនិងអវយវ:ទាំងអស់ត្រូវកំណត់ដឹង ។ គ- កំណត់ពិចារណានូវកាយ ប្រកបដោយអាការ:៣២ មានកេសា លោមា នខា ទន្តា តចោ គឺសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម ថាជាវត្ថុពុំស្អាត ។ ឃ- កំណត់ពិចារណានូវរូបរាងកាយថា គ្រាន់តែជាធាតុ៤ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ប៉ុណ្ណោះ ពុំមែនជាសត្វជាបុគ្គលមានសភាពសោះសូន្យទទេ, ង- ពិចារណានូវអសុភ១០ មានអសុភហើមប៉ោងរហូតដល់អសុភមានតែរាងឆ្អឹងមកប្រៀបធៀបនឹងខ្លួនឯង ថាជាវត្ថុពុំស្អាត ។ សតិបដ្ឋានទី២ហៅថា វេទនានុបស្សនាសតិបដ្ឋាន ប្រែថាការដំកល់ស្មារតីពិចារណារឿយៗនូវវេទនា ។ វេទនាប្រែថា ការដឹងឬការទទួលអារម្មណ៍ជាសុខជាទុក្ខ, ការទទួលអារម្មណ៍ជាសុខជាទុក្ខតាមផ្លូវកាយត្រូវកំណត់ដឹង ។ សោមនស្សទោមនស្ស ឬឧបេក្ខាតាមផ្លូវចិត្តត្រូវកំណត់ដឹងថា គ្រាន់តែជាវេទនាប៉ុណ្ណោះ ។ សតិបដ្ឋានទី៣ហៅថា ចិត្តានុបស្សនាសតិបដ្ឋាន ប្រែថាការដំកល់សារតីពិចារណារឿយៗនូវចិត្ត ។ ចិត្តមាន៤ប្រភេទ គឺកាមាវចរចិត្តជាចិត្តរបស់កាមាវចរសត្វ ដែលប្រព្រឹត្តនៅក្នុងរូបសម្លេងក្លិនរសសម្ផស្ស, រូបាវចរចិត្ត ជាចិត្តដែលប្រព្រឹត្តនៅក្នុងរូបជ្ឈាន, អរូបាវចរចិត្ត ជាចិត្តដែលប្រព្រឹត្តទៅក្នុងអរូបជ្ឈាន, លោកុត្តរចិត្ត ជាចិត្តដែលឆ្លងចាកភពបី ត្រូវកំណត់ដឹងតាមប្រភេទចិត្តដែលកើតឡើង ។ សតិបដ្ឋានទី៤ហៅថា ធម្មានុបស្សនាសតិបដ្ឋាន ប្រែថាការដំកល់សតិពិចារណារឿងៗនូវធម៌ ។ ធម៌ក្នុងទីនេះសំដៅយក នីវរណធម៌៥, ឧបាទានក្ខន្ធ៥, អាយតន:១២, ពោជ្ឈង្គ៧ និងអរិយសច្ច៤ ។ នីវរណធម៌៥គឺ កាមច្ឆន្ទ:, ព្យាបាទ:, ថីនមិទ្ធ:, ឧទ្ធច្ចកុក្កុច្ច: និង វិចិកិច្ឆា ។ ខន្ធ៥គឺ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ អាយតន:១២គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មនោ រូប សម្លេង ក្លិន រសសម្ផស្ស និងធម្ម: ។ ពោជ្ឈង្គ: ប្រែថាធម៌ជាអង្គនៃការត្រាស់ដឹងមាន សតិសម្ពោជ្ឈង្គ: ជាដើម ។ ធម៌ទាំងអស់នេះ ទាំងកុសលទាំងអកុសលកើតឡើងត្រូវកំណត់ដឹង ។ ធម្មាក្នុងសតិបដ្ឋានទី៤នេះ សំដៅយកវត្ថុដែលចិត្តតោងមកជាអារម្មណ៍ ។

ការកំណត់ពិចារណាតាមសតិបដ្ឋាន៤នេះ ដើម្បីឲ្យកើតសតិបញ្ញាកើតសម្បជញ្ញ: ឃើញការកើតរលត់របស់សង្ខារដែលពុំមែនជាតួខ្លួនទេ ។ សតិបដ្ឋាននេះបានត្រូវអ្នកដឹកនាំវិបស្សនាជាតិភូមាសំរួលធ្វើហៅថា ប៉ោងផត ហើយថែយកមកបន្ថែមថា ប៉ោងហ្ន៎ផតហ្ន៎ ។ ការកំណត់ពិចារណានេះដើម្បីឲ្យចូលក្នុងលក្ខណ: អនិច្ចំ ទុក្ខំ និង អនត្តា ដែលជាលក្ខណ:របស់វិបស្សនា ។ ក្នុងសូត្រនេះបានបញ្ជាក់ថា បុគ្គលដែលចំរើននូវសតិបដ្ឋានឲ្យបានម៉ត់ចត់ អាចសំរេចជាព្រះអរហន្ត ឬជាអនាគាមីក្នុងរវាង៩ឆ្នាំ ឬ៧ខែ ឬ៧ថ្ងៃ បើមានឧបនិស្ស័យពីមុនផងរំផង ។

### សេចក្តីសង្ខេប

សតិបដ្ឋាន ប្រែថាតាំងស្មារតី គឺសតិពិចារណាកំណត់ដល់នូវកាយ វេទនា ចិត្ត និង ធម្ម: ។ ការពិចារណាកាយ គឺគ្រប់ចលនារាងកាយត្រូវកំណត់ដឹង ។ វេទនា ជាសុខជាទុក្ខប្រព្រឹត្តទៅតាមផ្លូវកាយនិងសោមនស្ស ទោមនស្ស ឧបេក្ខា ប្រព្រឹត្តទៅតាមផ្លូវចិត្តត្រូវកំណត់ដឹង ។ ចិត្តនឹកគិតទៅរកវត្ថុណា ត្រូវកំណត់ដឹង ។ ធម្ម: បានដល់អ្វីដែលចិត្តអាចនឹកគិតបាន ត្រូវកំណត់ដឹង ។ ត្រូវកំណត់ថា កាយ វេទនា ចិត្ត និង ធម្ម: គ្រាន់តែជាកាយជាវេទនាជាចិត្តជាធម្ម:ប៉ុណ្ណោះ ពុំមែនជាសត្វជាបុគ្គលមានសភាសោះសូន្យទទេ ។ ការចំរើនសតិបដ្ឋាននេះ អាចធ្វើបានគ្រប់ឥរិយាបថទាំង៤ គឺដេកដើរឈរអង្គុយ ។ ការកំណត់តាមសតិបដ្ឋានទាំង៤នេះ ក្រៅពីឥរិយាបថអង្គុយ គេអាចដើរចង្ក្រមយ៉ាងយឺតៗ កំណត់ឆ្វេងស្តាំតាមជំហានដែលឈានទៅ ។ វិធីចង្ក្រមអាចធ្វើចិត្តឲ្យឆាប់មូលល្អ ។

ការកំណត់ស្មារតីតាមសតិបដ្ឋាន៤នេះ បើគិតទៅតាមផ្លូវលោកវិញមានប្រយោជន៍ណាស់ដល់សង្គមមនុស្សព្រោះអ្នកចំរើនសតិបដ្ឋាន៤តែងមានស្មារតីដ៏ល្អ មិនភ្លាំងភ្លេច មិនវង្វេងស្មារតី ហើយជាអ្នកពុំសូវលោភ ពុំសូវក្រោធផង ដែលជាសមាជិកដ៏ល្អរបស់សង្គម ។ បើមានសមាជិកសង្គមដ៏ល្អច្រើនគ្នា នាំឲ្យសង្គមលូតលាស់ខាងសីលធម៌ ហើយជំរុញឲ្យលូតលាស់ខាងសម្ភារ:ផង ។៚

○